ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការបន្ថែមសមាជិកគណៈកម្មការរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងជូ ២០០៦
## (Organizing Committee for Angkor – Gyeongju World Culture EXPO 2006)
## នៅខេត្តសៀមរាប ឆ្នាំ២០០៦-២០០៧

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស /៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស /រកម /០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៤៤ សសរ ស្តីពីការបង្កើតគណៈកម្មការរៀបចំពិព័រណ៍វប្បធម៌ពិភពលោក អង្គរ-ឃ្យុងជូ ២០០៦ នៅខេត្តសៀមរាប ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥
- យោងតាមតំរូវការចាំបាច់

## ស ម្រេ ច

**ប្រការ ១ :** បន្ថែមសមាជិកគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំពិព័រណ៍វប្បធម៌ពិភពលោក នៅខេត្តសៀមរាប ឆ្នាំ២០០៦ មានឈ្មោះថា **Angkor – Gyeongju World Culutre EXPO** មានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ឃឹម សារិទ្ធ** | រដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ២- ឯកឧត្តម **សុខ ផេង** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៣-ឯកឧត្តម **សួស យ៉ារ៉ា** | អគ្គលេខាធិការរងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា | សមាជិក និងជាសហប្រធានប្រតិបត្តិលេខាធិការដ្ឋានជាមួយភាគីកូរ៉េ |

/1

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ប្រធានអគ្គាយកអាជ្ញាធរអប្សរា អាជ្ញាធរជាតិទេសចរណ៍កម្ពុជា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទិចាត់ការគយ និងរដ្ឋាករ សាលាខេត្តសៀមរាប ប្រធាន អនុប្រធាន និង សមាជិកគណៈកម្មាធិការ ដែលមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ